ការបកប្រែក្រៅផ្លូវការ

ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

តាងនាមអោយរាជរដ្ឋាភិបាល និងប្រជាជននៃព្រះរាជាណាចក្រថៃ ខ្ញុំសូមសម្តែងនូវការជូនពរយ៉ាងកក់ក្តៅចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងតាមរយៈ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ចំពោះរាជរដ្ឋាភិបាល និងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងឱកាសដ៏សោមនស្សរីករាយក្នុងឱកាសគម្រប់ខួបលើកទី ៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០ នេះ។

មើលត្រលប់ថយក្រោយវិញ ប្រទេសយើងទាំងពីរបានឆ្លងកាត់នូវដំណើរផ្លូវដ៏វែងឆ្ងាយ។ តាមរយៈ "ភាពជាដៃគូដើម្បីសន្តិភាពនិងវិបុលភាព" យើងបានធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍដែលបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនរបស់យើង និងលើសពីនេះ។

ក្នុងឱកាសដ៏មហាវិសេសវិសាលក្នុងឱកាសគម្រប់ខួបលើកទី ៧០ នៃទំនាក់ទំនងការទូតរវាងប្រទេសយើងទាំងពីរ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលចំណងមិត្តភាពរបស់យើងមានភាពស្អិតរមួត និងរឹងមាំ ដោយមានការធ្វើកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ និងគ្រប់កម្រិតទាំងអស់។ រួមជាមួយគ្នា យើងបានសហការគ្នាដើម្បីជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ក្រសួង/ស្ថាប័ននានា និងការតភ្ជាប់រវាងប្រជាជននិងប្រជាជនផងដែរ។ លើសពីនេះ យើងបានវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់លើមូលធនមនុស្ស ដោយបានផ្តល់អាហារូបករណ៍ជាង ២,៤០០ កន្លែង ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ បន្ថែមលើសពីនេះ ទោះបីជាមានការកើតមានឡើងនៃជំងឺឆ្លងផ្សេងៗ រួមមានជំងឺកូវីដ-១៩ ក៏ដោយ ក៏យើងបានពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសុខភាពសាធារណៈ ជាពិសេសនៅតំបន់នានាតាមបណ្តោយព្រំដែន។ ជាការពិតណាស់ កិច្ចសហការរបស់យើងនៅក្នុងវិស័យផ្សេងៗ បាននាំមកនូវការផ្លាស់ប្តូរយ៉ាងជាក់ស្តែងដែលធ្វើអោយជីវភាពរស់នៅរបស់ប្រជាជនមានភាពប្រសើរឡើង។

នៅថ្ងៃមុខ ខ្ញុំជឿជាក់ថា ភាពជាដៃគូដ៏រឹងមាំរបស់យើងនឹងនៅតែបន្តរីកចម្រើន ដោយពឹងផ្អែកលើភាពជឿទុកចិត្តនិងសុច្ឆន្ទៈដែលយើងបានសាងមកក្នុងរយៈពេល ៧០ ឆ្នាំ នេះ និងនៅក្នុងឆ្នាំបន្តបន្ទាប់ទៀត។ លើសពីនេះ យុវជនជំនាន់ក្រោយនឹងបន្តរក្សាមិត្តភាពរបស់យើងឱ្យនៅឋិតថេរ គង់វង្ស និងរឹតតែរឹងមាំថែមទៀត។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

**ឯកឧត្តម ដន ប្រាម៉ាត់វីណៃ**

**ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស**

**នៃព្រះរាជាណាចក្រថៃ**